មូលនិធិខ្មែរសម្រាប់ការសិក្សា
Cambodian Education Excellence Foundation
ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា Equal Education Opportunity for All.
12739 Knightsbridge Drive, Woodbridge, VA 22192. Tel: (703) 670-0854. ceefusa@ceefoundation.org www.ceefoundation.org

# កិច្ចស្វាគមន៍របស់លោក អ៊ុំ សង់អុន

តំណាងអង្គការមូលនិធិខ្មែរសំរាប់ការសិក្សាប្រចាំនៅកម្ពុជា
នៅក្នុងឱកាសផ្តល់អាហារូបករណ៍ជូនចំពោះនិស្សិតខ្មែរក្រីក្រនិងរៀនពូកែ
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

សូមគោរពឯកឧត្តម អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលមានវត្តមាននៅនេះ
សូមស្វាគមន៍ក្មួយៗនិស្សិតទាំងអស់

ថ្ងៃនេះជាឱកាសដ៏សប្បាយរីករាយជាទីបំផុត ដែលខ្ញុំបាទ ក្នុងនាមអោយមូលធិនិខ្មែរសំរាប់ការសិក្សា បានចូលរួមនៅក្នុងឱកាសផ្តល់អាហារូបករណ៍ដល់ក្មួយៗនិស្សិតខ្មែរក្រីក្រនិងតស៊ូព្យាយាមរៀនសូត្រ ដែលមកពីបណ្តាសាកលវិទ្យាល័យផ្សេងៗ នៅក្នុងទីក្រុងភ្នំពេញ ដែលមានសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យបៀលប្រាយ និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ ហើយមូលនិធិខ្មែរសំរាប់ការសិក្សា ក៏មានគំរោងនឹងផ្តល់អាហារូបករណ៍នេះចំពោះនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៅក្នុងខេត្តនានាផងដែរ រួមមានខេត្តព្រៃវែងជាដើម។ ហើយខ្ញុំសូមកោតសសើរយ៉ាងខ្លាំង ចំពោះក្មួយៗនិស្សិតទាំងអស់ ដែលបានព្យាយាមនិងពុះពារនូវរាល់ឧបសគ្គ ទាំងឡាយ រហូតដល់បានឈានជើងចូលរៀននៅមហាវិទ្យាល័យ។ ចំណេះដឹងពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីកសាងអនាគតរបស់ក្មួយៗទាំងអស់គ្នាក៏ដូចជាការកសាងប្រទេសជាតិរបស់យើងផងដែរ។

ឆ្លៀតនៅក្នុងឱកាសនេះផងដែរ ខ្ញុំបាទសូមជំរាបជូនដោយសង្ខេប នូវការកកើតនូវមូលនិធិសំរាប់ការសិក្សានេះឡើង ហើយដែលបានឈានរហូតមកដល់សព្វថ្ងៃនេះ។ មូលនិធិខ្មែរសំរាប់ការសិក្សានេះ ត្រូវបានបង្កើតឡើងដោយប្រជាពលរដ្ឋខ្មែរមួយចំនួន នៅសហរដ្ឋអាមេរិក ដែលមានទឹកចិត្តចង់បណ្តុះបណ្តាលដល់កូនខ្មែរ ដែលជួបប្រទះនូវការលំបាកក្នុងការបន្តការសិក្សា ហើយដែលមានចិត្តតស៊ូនិងព្យាយាមក្នុងការសិក្សា ដើម្បីបន្តការសិក្សាប្រកបដោយជោគជ័យ។

មូលនិធិខ្មែរសំរាប់ការសិក្សាទទួលបានជោគជ័យដូចពេលនេះ ក៏ដោយសារការខិតខំប្រឹងប្រែង និងការសហការពីសំណាក់សាកលវិទ្យាល័យ ក្នុងការជ្រើសរើសនិស្សិតផងដែរ ហើយតាងនាមអោយមូលនិធិខ្មែរសំរាប់ការសិក្សាប្រចាំនៅកម្ពុជា ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាកលវិទ្យាល័យទាំងអស់ និងសូមអោយបន្តការសហការគ្នាជាបន្តទៅទៀត ដើម្បីចូលរួមជួយដល់និស្សិតខ្មែរយើងដើម្បីអោយទទួលបានជោគជ័យនៅក្នុងការសិក្សា។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់បងៗនៅឯនាយសមុទ្រ ដែលបានខិតខំស្វែងរកប្រាក់ជំនួយ និងអរគុណចំពោះសប្បុរសជនដែលបានផ្តល់ថវិកាសំរាប់ជួយដល់ក្មួយៗនិស្សិតទាំងអស់ផងដែរ។

ជាចុងក្រោយ ខ្ញុំបាទក៏សូមផ្តាំផ្ញើទៅកាន់ក្មួយៗនិស្សិតទាំងអស់ ក្រោយពីទទួលបានអាហារូបករណ៍ហើយ ត្រូវប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ដើម្បីបំរើការសិក្សារបស់ខ្លួន អោយកាន់តែប្រសើរឡើង និងត្រូវខិតខំសិក្សាបន្ថែមទៀត ដើម្បីយកចំណេះដឹងទាំងនេះ បំរើអោយក្រុមគ្រួសារ និងសង្គមជាតិទាំងមូលផងដែរ និងសូមជូនពរ រីករាយឆ្នាំថ្មី សូមអោយមានសុខភាពមាំមួន ពោលគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លាងឃ្លាត។

សូមអរគុណ